# សុន្ទរកថាបើកសន្និបាត
# គណៈកម្មាធិការកណ្ដាលលើកទី ២៤ បើកទូលាយ
# ថ្លែងដោយសម្ដេច ជា ស៊ីម ប្រធានគណបក្ស
# (ថ្ងៃទី ៣-៤-៥-៦ ខែ មិនា ឆ្នាំ ១៩៩៨)

សូមគោរពគណៈអធិបតី !

សម្ដេច ឯកឧត្ដម លោកជំទាវ សមាជិក សមាជិកានៃអង្គសន្និបាតជាទីស្នេហា !

ថ្ងៃនេះយើងប្រារព្ធធ្វើសន្និបាតគណៈកម្មាធិការកណ្ដាលលើកទី ២៤ បើកទូលាយ ស្របពេលដែលសភាពការណ៍ឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រសំរាប់អាណត្តិថ្មីនាថ្ងៃទី ២៦ កក្កដា ឆ្នាំ ១៩៩៨ នេះ កំពុងទាក់ទាញសាធារណមតិជាតិ និង អន្តជាតិ ឱ្យមានការចាប់អារម្មណ៍ជាទូទៅ ។

ក្រោយសន្និបាតគណៈកម្មាធិការកណ្ដាលលើកទី ២៣ នាចុងខែ ១០ ឆ្នាំ ១៩៩៧ កំលាំងសាមគ្គីរបស់គណបក្សទាំងមូល បានប្រមូលផ្ដុំអនុវត្តទិសដៅភារកិច្ចដែលសន្និបាតបានកំណត់ ។ គណៈអចិន្ត្រៃយ៍បានចាត់តាំងធ្វើសិក្ខាសាលា និងអង្គប្រជុំជាបន្តបន្ទាប់ ដើម្បីប្រមូលផ្ដុំបញ្ញាញាណរបស់សមូហភាពចូលរួមក្នុងការកសាងគោលការណ៍ដឹកនាំរបស់គណបក្សក្នុងសភាពការណ៍ថ្មី ។ ជោគជ័យសំខាន់ៗនៃការអនុវត្តសេចក្ដីសំរេចចិត្តរបស់សន្និបាតគណៈកម្មាធិការកណ្ដាលលើកទី ២៣ គឺការបន្តធ្វើឱ្យមានលំនឹងនៃស្ថិរភាពនយោបាយ ការគោរពរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ការពង្រឹងសន្តិភាព ការគោរពសិទ្ធិមនុស្ស ការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការបន្តនិរន្តរភាពរាល់ស្ថាប័នកំពូលរបស់រដ្ឋ និងការបន្តកសាងនីតិរដ្ឋ ។ លើសពីនេះទៀត យើងបានរួមចំណែកយ៉ាងសំខាន់ក្នុងការធ្វើឱ្យសេដ្ឋកិច្ចសង្គមនៅរក្សាដំណើរការធម្មតា ដោយបញ្ចៀសបានជាអតិបរិមានូវផលវិបាកដែលបណ្ដាលមកពីវិបត្តិសេដ្ឋកិច្ចរបស់បណ្ដាប្រទេសក្នុងតំបន់ និងបន្ថែមដោយការខិតខំកសាងនូវរាល់សមិទ្ធិផលផ្សេងទៀត ដូចជាការដោះស្រាយបញ្ហាទឹក ភ្លើង ផ្លូវថ្នល់ សំណង់សាធារណៈ ការជួយដោះស្រាយនូវការលំបាករបស់ប្រជាជន ។ល។

គណបក្សប្រជាជន សូមវាយតម្លៃខ្ពស់ចំពោះការខិតខំរបស់រាជរដ្ឋាភិបាលក្នុងការដោះស្រាយនូវបញ្ហាសំខាន់ៗ ដើម្បីបង្កនូវបរិយាកាសនយោបាយអព្យាក្រិតសំរាប់ការបោះឆ្នោត ។ គណបក្សប្រជាជនកម្ពុជា សូមសំដែងនូវកត្តញ្ញូតាធម៌ចំពោះរដ្ឋសភា ដែលបានអនុម័តនូវច្បាប់ស្ដីពីគណបក្សនយោបាយ ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបង្កើតគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ល។ ដែលជាគោលការណ៍ចំបងធានាបានការប្រព្រឹត្តទៅនៃការបោះឆ្នោត ដែលជាការទន្ទឹងរង់ចាំនៃមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ។

មកដល់ពេលនេះ គណបក្សប្រជាជនកម្ពុជាបានត្រៀមរៀបចំខ្លួនរួចហើយ ដើម្បីចូលរួមជាមួយគណបក្សនយោបាយទាំងចាស់ ទាំងថ្មីដែលស្របច្បាប់ ដើម្បីចូលរួមប្រកួតប្រជែងបោះឆ្នោតតាមការកំណត់នៃច្បាប់ និងតាមការរៀបចំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយសង្ឃឹមថាការបោះឆ្នោតលើកនេះនឹងប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងអាចទុកចិត្តបានគ្រប់ៗគ្នា ។

គណបក្សប្រជាជនកម្ពុជា សូមកោតសរសើរចំពោះបងប្អូនជនរួមជាតិទាំងអស់ ដែលបានរួមគ្នាការពារដំណើរជាតិកម្ពុជាបានឈានទៅមុខស្របតាមសំណូមពររបស់ប្រជាជនកម្ពុជា និងស្របតាមនិន្នាការរួមរបស់ពិភពលោក ។

គណបក្សប្រជាជនកម្ពុជា សូមស្វាគមន៍ចំពោះការវិលត្រលប់វិញរបស់អ្នកនយោបាយទាំងអស់ ដើម្បីរួមគ្នាធ្វើការបំរើផលប្រយោជន៍របស់ជាតិយើង ហើយយើងទាំងអស់គ្នានឹងទទួលបាននូវសិទ្ធិសេរីភាពខាងនយោបាយដូចៗគ្នា ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

គណបក្សប្រជាជនកម្ពុជា អបអរសាទរចំពោះប្រទេសជាមិត្តជិតឆ្ងាយដែលបានបន្តផ្តល់ជំនួយ និងការគាំទ្រដល់បុព្វហេតុជាតិ និងប្រជាជនកម្ពុជា ។ សូមស្វាគមន៍ចំពោះសហគមន៍អន្តរជាតិ ដែលបានរួមចំណែកដល់សន្តិភាព និងស្ថិរភាពនៅកម្ពុជា ដោយឈរលើគោលការណ៍គោរពអធិបតេយ្យជាតិ និងសិទ្ធិស្វ័យសំរេចរបស់កម្ពុជា ពិសេសសូមសំដែងនូវកត្តញ្ញូតាធមិដ៏ជ្រាលជ្រៅចំពោះការជួយឧបត្ថម្ភទាំងស្មារតី និងសម្ភារៈ ដល់ដំណើរការបោះឆ្នោតនាពេលខាងមុខនេះ ។

គណបក្សប្រជាជនកម្ពុជា សូមគាំទ្រនូវសំណើ ៤ ចំណុចរបស់ជប៉ុន ដែលបានលើកឡើងដោយ សម្តេច ហ៊ុន សែន ក្នុងឱកាសសវនាការជាមួយអនុរដ្ឋមន្ត្រីការបរទេសជប៉ុន នាថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ។

ក្នុងឱកាសនេះ ខ្ញុំសូមវាយតំលៃខ្ពស់ និងកោតសសើរ ចំពោះគណៈកម្មាធិការគណបក្សគ្រប់ថ្នាក់ មន្ត្រីសមាជិក សមាជិកាគណបក្សគ្រប់រូប ដែលបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តន៍រាល់ភារកិច្ចនយោបាយរបស់គណបក្ស ហើយទទួលបានលទ្ធផលល្អប្រសើរ ។

ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ សន្និបាតគណៈកម្មាធិការលើកទី ២៤ បើកទូលាយលើកនេះ មានភារកិច្ចពិនិត្យឆ្លង និងអនុម័តរបាយការណ៍ស្តីពីសភាពការណ៍ និងការងាររបស់គណបក្សតាំងពីក្រោយសន្និបាតគណៈកម្មាធិការកណ្តាលលើកទី ២៣ ទិសដៅភារកិច្ចសំរាប់រយៈពេលបន្ត ដែលមានអត្ថន័យសំខាន់ដល់ការត្រៀមគ្រប់លក្ខណៈសម្បត្តិរបស់គណបក្សយើង ដើម្បីចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត ។

នៅក្នុងសន្និបាតលើកនេះដែរ តាមសំណូមពររបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល អាស្រ័យដោយកម្មវិធីនយោបាយ និងគោលការណ៍គោលនយោបាយធំៗរបស់គណបក្សពុំទាន់មានអ្វីផ្លាស់ប្តូរនោះ អង្គសន្និបាតនិងពិនិត្យសំរេចអំពីការពន្យាពេលបើកមហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេសរបស់គណបក្ស ដែលសន្និបាតគណៈកម្មាធិការកណ្តាលលើកទី ២៣ បានកំណត់ធ្វើនៅក្នុងត្រីមាសទី ១ នៃឆ្នាំ ១៩៩៨ នេះ ទៅធ្វើនៅពេលក្រោយវិញ ។

សន្និបាត នឹងដំណើរការរយៈពេល ៤ ថ្ងៃ តាមរបៀបវារៈដែលបានកំណត់ ។

សមាជិកគណៈកម្មាធិការកណ្ដាលចូលរួមសន្និបាតមានវត្តមានចំនួន ១៤៥ រូប អវត្តមានចំនួន ៨ រូប ។ អាស្រ័យដោយសន្និបាតលើកនេះ ជាសន្និបាតគណៈកម្មាធិការកណ្ដាលបើកទូលាយ គណៈអចិន្ត្រៃយ៍ក៏បានអញ្ជើញមន្ត្រីគណបក្សជាសមាជិកសភា តំណាងគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ទីប្រឹក្សាតំណាងគណបក្សនៅអាមេរិក បារាំង អូស្ត្រាលី ចំនួន ៥៧៥ រូបទៀត ចូលរួមសន្និបាតលើកនេះផងដែរ ។

ខ្ញុំសូមប្រកាសបើកសន្និបាត និងសូមប្រសិទ្ធិពរ ឱ្យអង្គសន្និបាតប្រព្រឹត្តទៅដោយជោគជ័យ ។

**សូមអរគុណ !**